**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## មិនមានករណីជាសះស្បើយ និងមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី ០២នាក់
## នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

- ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២២០នាក់** (ស្មើនឹង ៨២,០៩% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៤៦នាក់ និងបុរស ១៧៤នាក់
- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៦៨នាក់** (ស្ត្រី ៥៣នាក់ និងបុរស ២១៥នាក់។
- អ្នកសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យរដ្ឋ និងឯកជន មានចំនួនសរុប **៤៨នាក់៖**
  - នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចំនួន ០៣នាក់ (ស្ត្រីជនជាតិកាណាដា ០១នាក់ ស្ត្រីជាកងទ័ពម្ញកខៀវ ០១នាក់ និងស្ត្រីជនជាតិអាមេរិកកាំង ០១នាក់)
  - នៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ មានចំនួន ៤០នាក់ (ស្ត្រី ០៣នាក់ និងបុរស ៣៧នាក់ )
  - នៅមន្ទីរពេទ្យបង្អែកខេត្តកំពង់ស្ពឺ មានចំនួន ០១នាក់ ជាបុរស
  - នៅមន្ទីរពេទ្យបង្អែកខេត្តត្បូងឃ្មុំ មានចំនួន ០៣នាក់ ជាបុរស
  - នៅមន្ទីរពេទ្យរ៉ូយ៉ាល់ភ្នំពេញ ស្ត្រីជនជាតិកាហ្សាក់ស្ថង់ មានចំនួន **០១នាក់**

**២. ករណីវិជ្ជមានវីរុសកូវីដ-១៩ថ្មី៖** ចំនួន០២នាក់ (ជនជាតិចិន០១នាក់ និងជនជាតិអាមេរិកកាំង០១នាក់)

-បុរសជនជាតិចិនអាយុ ២២ឆ្នាំ ស្នាក់នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ ដើម្បីធ្វើចត្តាឡីស័កចំនួន ១៤ ថ្ងៃ ជាអ្នកដែលបានធ្វើដំណើរមកពីប្រទេសហ្វីលីពីន តាមជើងហោះហើរ មកដល់កម្ពុជា នៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០២០ ត្រូវបានធ្វើតេស្តលើកទីពីរដោយទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ ហើយបច្ចុប្បន្ន អ្នកជំងឺត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែ រាជធានីភ្នំពេញ។

- ស្ត្រីជនជាតិអាមេរិកកាំងអាយុ ២៥ឆ្នាំ មានអាសយដ្ឋានស្នាក់នៅរាជធានីភ្នំពេញ ជាអ្នកដំណើរមកពី



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ៨០ វិថីសម្តេចប៉ែននុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: [illegible]

សហរដ្ឋអាមេរិក បន្តជើងហោះហើរនៅប្រទេសកូរ៉េខាងត្បូង មកដល់កម្ពុជានៅថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២០ ដែលការធ្វើតេស្តពេលមកដល់របស់គាត់ ទទួលបានលទ្ធផល វិជ្ជមានវីរុសកូវីដ-១៩ ត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត។ សូមកត់សម្គាល់ថា ជើងហោះហើរនេះមានអ្នកដំណើរសរុប ២៥នាក់ (ស្រី ០៧នាក់ បុរស ០៩នាក់ និងកុមារ ០៩នាក់) ក្នុងនោះមានជនជាតិខ្មែរ ១៤នាក់ ជនជាតិអាមេរិកកាំង ០៥នាក់ ជនជាតិកូរ៉េខាងត្បូង ០១នាក់ ជនជាតិវៀតណាម ០១នាក់ ជនជាតិថៃ ០១នាក់ ជនជាតិទួកគី ០១នាក់ និងជនជាតិអង់គ្លេស ០២នាក់។ ចំណែកឯអ្នកដំណើរដែលមានលទ្ធផលតេស្ត អវិជ្ជមានវីរុសកូវីដ-១៩ ចំនួន ២១នាក់ ត្រូវបានដាក់ឲ្យធ្វើចត្តាឡីស័កចំនួន ១៤ថ្ងៃ នៅសណ្ឋាគារមួយក្នុងរាជធានីភ្នំពេញ និងមន្ត្រីស្ថានទូតអាមេរិកចំនួន ០៣នាក់ ស្នាក់នៅក្នុងស្ថានទូតអាមេរិកប្រចាំកម្ពុជា ដែលគ្រប់គ្រងដោយស្ថានទូតអាមេរិកប្រចាំកម្ពុជា។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃពុធ ៨រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០